# គូបដិបក្ខនៃអង្គវត្ថុ

(Opponents of an object)

ដោយៈ បណ្ឌិត **ភ្លាន់ ធុល**
មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា
វិទ្យាស្ថានមនុសាស្ត្រនិងវិទ្យាសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១. សេចក្តីផ្តើម

*គេនិយាយថា ការងារបង្រៀន មនុស្ស ហើយបន្ទាប់មកមនុស្សបាន បង្រៀនការងារ ទៅដល់មនុស្ស។ កាល ពីសម័យកុម្មុយនិស្ត បុព្វកាល មនុស្សកើត ឡើងដំបូងមិនទាន់ចេះធ្វើអ្វីៗនៅឡើយទេ។ ពួកគេរស់នៅក្នុងធម្មជាតិ ក្នុងសភាពជា សត្វដែលខុសប្លែកពីមនុស្ស។ បន្ទាប់ពីពួក គេរស់នៅក្នុងធម្មជាតិអស់រយៈពេលដ៏ យូរ ធម្មជាតិបានបង្រៀនមនុស្សឱ្យចេះគិត ដោយចាប់ផ្តើមពី* ***ចម្ងល់មិនចេះចប់***។ *ជាបន្តបន្ទាប់ ពួកគេក៏ចេះគិតនិងចេះស្វែងរកការរស់នៅមួយកាន់តែប្រសើរឡើងៗ។ អភិវឌ្ឍន៍គំនិតគឺជាប្រភពនៃអភិវឌ្ឍន៍ ទ្រឹស្តី និងអនុវត្តន៍ ដែលជាប្រភពមូលដ្ឋានរបស់* ***ទស្សនវិជ្ជា*** (philosophies) *និង* ***វិទ្យាសាស្ត្រ*** (sciences)។ *ការគិតរកសច្ចភាព មនុស្សបានប្រើវិធីជាច្រើន មានវិធី អនុមានរួម វិធីអនុមានញែក...ល...។ ដែលនៅក្នុងនោះ* ***វិធីបដិសំយោគ*** *ជាវិធីសំខាន់មួយដែលទស្សនវិទូបានបង្កើតឡើង ដើម្បីប្រើប្រាស់ក្នុងការស្វែងយល់ ពី* **គូបដិបក្ខ** *និង* ***ការតស៊ូ*** *នៃអង្គវត្ថុ,* ***ការ សំយោគ*** *និង* ***ការបំបែក***, ***តម្រូវការ*** *និង* ***ការបំពេញឱ្យគ្នា*** *របស់ពួកវា។*

## ២. ទ្រឹស្តីគូបដិបក្ខ

*នៅក្នុងប្រធានបទដែលលើកឡើងពីគូបដិបក្ខនៃអង្គវត្ថុ ខ្ញុំមានការបកស្រាយ ពន្យល់នៅក្នុងទ្រឹស្តី៣។ ទ្រឹស្តីទី១ គឺ ទ្រឹស្តី បដិសំយោគរបស់ ហេហ្គិល និង កាល ម៉ាក្ស; ទ្រឹស្តីទី២ គឺ ទ្រឹស្តីគូបដិបក្ខនៃសម្ព័ន្ធ ផៃសាហ្គរាននិយម* (Pythagoreanism; *និង ទ្រឹស្តីទី៣ គឺ ទ្រឹស្តីគូបដិបក្ខនៃលោកធម៌ ទាំង៨គូ នៅក្នុងព្រះពុទ្ធសាសនា។*

### ២.១. ទ្រឹស្តីបដិសំយោគ

***ទ្រឹស្តីបដិសំយោគ*** *ត្រូវបានគេស្គាល់ជាទូទៅថា ជាដំណើរឈានទៅដល់* ***ពុទ្ធិ*** *តាមរយៈ* ***បច្ចេកទេសសំណួរ-ចម្លើយ*** (question - and - answer technique) ។ ***ហេហ្គិល*** (Hegel) *បានពិពណ៌នាវិធីនេះថា ជាទម្រង់ការមួយដែល* ***គំនិត*** (thought) *ឬ* ***វត្ថុអត្ថិភាពមួយ*** (existing thing) *ដែលគេហៅថា* ***ទស្សនកថា***

(thesis) ដឹកនាំ និង ផ្លាស់ប្ដូរយ៉ាងចាំបាច់ទៅរក **គំនិតផ្ទុយ** (contradictory idea) ដែលគេហៅថា **ប្រតិទស្សនកថា** (antithesis) ដោយហេតុនេះ ហើយទើប **គំនិត ឬវត្ថុថ្មី** (new thought or thing) ដែលអាចឱ្យគេហៅថា **សំយោគទស្សនកថា** (synthesis) បានកើតឡើង។ ដំណើរនេះ ចាប់ផ្ដើមឡើងតាមរយៈអំណះ អំណាងមួយអំពីអ្វីមួយ (ទស្សនកថា) ដែលមានលក្ខណៈ មិនពេញលេញ (in-comeplete)។ អ្វីមួយដែលទាក់ទងទៅនឹង អំណះអំណាងនោះ ត្រូវបានគេលុបចោល (ប្រតិទស្សនកថា)។ **អង្គបដិបក្ខ** (conflict) ដែលគេហៅថាជា **បដិសំយោគ** (dialectic) រវាងអ្វីដែលគេបានអះអាង ហើយនិងអ្វី ដែលគេបានលុបចោលនោះមានអត្ថិភាព។ ដោយសារ **អង្គបដិបក្ខ** នេះហើយ ទើប លេចឡើងនូវ **សំណើទី៣ថែមមួយទៀត** នោះគឺ **សំយោគទស្សនកថា** (synthesis) ដែលលុបព្រំដែន **ទស្សនកថា** (the limita- tion of the thesis) និង **ប្រតិទស្សនកថា** (the antithesis) ចោល ប៉ុន្តែវានៅតែថែរក្សាតម្លៃឱ្យគ្នាដដែល[១]។

**ម៉ាក្ស** (Marx) និង **ហេហ្គិល** បានប្រើ **ទ្រឹស្ដីបដិសំយោគ** (Dialectic) នេះ ដើម្បីវិភាគទៅលើ **អភិវឌ្ឍន៍សង្គមកុំម្មុយ នីស្ត** របស់ពួកលោក។ លោកទាំងពីរបាន បង្កើតទ្រឹស្ដីថា **អង្គបដិបក្ខ** (conflict) កើតមានឡើងដោយសារមាន **វណ្ណៈសង្គមពីរ** (two social classes) គឺ **ពួកមូលធន** (ទស្សនកថា) និង **កម្មករស៊ីប្រាក់ឈ្នួល** (ប្រតិទស្សនកថា)។ **ការតស៊ូវណ្ណៈស្អិតរមួត** (បដិសំយោគ) មានអត្ថិភាពរវាងវណ្ណៈទាំងពីរ។ ចំណុចមួយដែលពួកគេនឹងឈានទៅដល់នោះ គឺចំនួនពួកកម្មករដែលមានកម្លាំងគ្រប់គ្រាន់ អាចគ្របសង្កត់ទៅលើ **ពួកមូលធននិយម** បាន។ ការតស៊ូនេះនឹងដឹកនាំឆ្ពោះទៅរកការបង្កើតសង្គមមួយថ្មី គឺ **សង្គមកុម្មុយនីស្ត** (communi-stic society) ឬ **សង្គមគ្មានវណ្ណៈ** (class-less society) [សំយោគទស្សនកថា (syn- thesis)][២]។

## ២.២. ទ្រឹស្ដីគូបដិបក្ខសម្ព័ន្ធផៃសាហ្គោរាននិយម

គូទំនាស់បើតាម**សម្ព័ន្ធផៃសាហ្គោរាននិយម** (Pythagoreanism: ៥៧១-៤៩៧ មុនគ.ស.) ដែលជាអង្គការទស្សនវិជ្ជានិង នយោបាយរបស់ **ផៃសាហ្គោរីស** (Pytha-goras) ទស្សនវិទូក្រិកបុរាណបានបង្កើត ប្រព័ន្ធគូបដិបក្ខមួយ ដែលមាន **១០គូបដិបក្ខ** ដោយចាប់ផ្ដើមពី **ចំនួន** (number)។ **ផៃសាហ្គោរីស** យល់ថា **សារជាតិនៃរាល់វត្ថុ** បានស្ដែងឡើងនៅក្នុង **ចំនួន**។ **ចំនួន** បានបង្កើត**ពិភពលោក** និងបង្កើត "**សណ្ដាប់ធ្នាប់សង្គម**"។ ការស្គាល់ **ចំនួន** គឺជាការស្គាល់ **ពិភពលោក**។ លោកបានធ្វើឱ្យ

[១] Venancio B. Ardales, *Introductory Text to Philosophy*, 2nd Ed., New York, 1987, p 30

[២] Venancio B. Ardales, *op.cit*,, p 31

**ចំនួន** មានលក្ខណៈអាថ៌កំបាំង មានសារជាតិអរូបីផ្តាច់ខ្លួនចេញពី **ទម្រង់រូបធាតុ**។ លោកបែងចែក **ចំនួន** តាមក្រុមដូចខាង ក្រោម៖

- "**ក្រុមបួន**" លេខ ១ ឬឯកតាជាចំណុច (point)
- លេខ ២ ជាខ្សែបន្ទាត់ (ligne)
- លេខ ៣ ជាផ្ទៃក្រឡា (surface)
- លេខ ៤ ជាមាឌ (Volume)[3]។

គេយល់ថា អង្គធាតុនីមួយៗសុទ្ធសឹងមាន **ចំណុច** ឬឯកតាក្នុងលំហ។ បណ្តុំចំណុចទាំងនោះក្លាយជាចំនួន។ ចំនួន បាន បង្ហាញឱ្យឃើញ ដោយ "**ក្រុមបួន**" ដែលក្រិកហៅថា **ថេត្រាកធីស** (Tetractys)។




ថេត្រាកធីស

**សម្ព័ន្ធផៃសាហ្គ្ករាននិយម** បញ្ជាក់ថា "**ក្រុមបួន**" ជាបាតុភូតចំឡែកមួយ ពីព្រោះ **ចំនួន ១០** គឺជាការបូកសរុបនៃ **ចំនួន ១, ២, ៣, និង៤**។ គេចាត់ទុក "**ក្រុម បួន**" ជា **អាទិទេព** ដែលបានអនុវត្ត ទស្សនៈគណិតវិទ្យាចូលទៅក្នុង **សណ្តាប់ ធ្នាប់នៃតថភាពរូបធាតុ**។ **ខ្សែបន្ទាត់** ជា **ចំណុច** ដ៏ច្រើនអនេក ដែលត្រូវបានតំរៀបជាបន្តបន្ទាប់គ្នា។ **ផ្ទៃក្រឡា** កើតឡើងដោយសារបន្សំនៃ **ខ្សែបន្ទាត់** ជាច្រើន។ **ផ្ទៃក្រឡា** រួមគ្នាជាច្រើនបង្កើតបានទៅជា **មាឌ**។ ហេតុនេះ គេយល់ថា **ចំណុច**, **ខ្សែ បន្ទាត់**, និង **ផ្ទៃក្រឡា** បានបង្កើត **រាល់វត្ថុធម្មជាតិ** ពោលគឺជាវត្ថុដែលមានម៉ាស់ មានលក្ខណៈទូលំទូលាយ ដែលគេអាចវាស់បាន។ "**ក្រុមដប់**" ជាចំនួនសុក្រិត្យបំផុត ជាមូលដ្ឋានសម្រាប់ពិចារណាអំពីចំនួនផ្សេងៗទៀត។ "**ក្រុមដប់**" ស្របនឹង **ភពដប់**។ អំពីទ្រឹស្តីស្តីពីផ្នែកបដិបក្ខវិញ និកាយនេះបានបង្កើតប្រព័ន្ធគូបដិបក្ខមួយដែលមាន **១០គូ** បដិបក្ខចម្បងគឺ៖

១- **ព្រំដែន និងឥតព្រំដែន**

២- **គត់ និងសេស**

៣- **ឯក និងពហុ**

៤- **ស្តាំ និងឆ្វេង**

៥- **បុរស និងស្ត្រី**

៦- **ចល័ត និងអចល័ត**

៧- **ត្រង់ និងកោង**

៨- **ភ្លឺ និងងងឹត**

៩- **ល្អ និងអាក្រក់**[4]

១០- **មុមបួន និងពហុមុខ**

---

[៣] ឆយ យីហ៊ាង, "ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជាបូរាណសម័យក្រិក",សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៤, ទំព័រ ១២

[៤] ឆយយីហ៊ាង,ដ.ឯ.ម, ទំព័រ ១២

នៅក្នុងគូបដិបក្ខទាំងដប់នេះ គូបដិបក្ខដែលមានអត្ថន័យសំខាន់បំផុតខាងទស្សនវិជ្ជាគឺ **គូបដិបក្ខទី១**។ ដោយផ្អែកលើ **គូបដិបក្ខទាំង១០** នេះ **សម្ព័ន្ធផែសាហ្គូរាននិយម** នេះ ពន្យល់ថា **តួរ្យតន្ត្រី** ជាបាតុភូតដែលស្ដែងឡើងយ៉ាងជាក់ច្បាស់ នៃបន្សំយ៉ាងស៊ីចង្វាក់គ្នានូវ **សំឡេង** ផ្សេងៗ។ **សំឡេង** ទាំងនោះចំណុះ **រង្វាស់ប្រវែងខ្សែតន្ត្រី**។ ហេតុនេះ **សារជាតិនៃសំឡេង** ត្រូវបានកំណត់ ដោយ **បរិមាណរង្វាស់ខ្សែតន្ត្រី**។ រីឯ **សារជាតិនៃតួរ្យតន្ត្រី** គឺជាបន្សំ យ៉ាងស៊ីចង្វាក់នូវ **សំឡេង** ទាំងឡាយដែលបានកើតចេញពី **រង្វាស់ប្រវែងនៃខ្សែតន្ត្រី** នោះ[៥]។

## ២.៣. ទ្រឹស្ដីគូបដិបក្ខនៃលោកធម៌ទាំង៤គូ

នៅក្នុងព្រះពុទ្ធសាសនា **សេចក្ដីទុក្ខ** និង **សេចក្ដីសុខ** របស់មនុស្សកើតឡើង មកពីផ្លូវចិត្តឡើងចុះទៅតាម **លោកធម៌ ទាំង៨** ដែលបង្រួមមកជា ៤ គូបដិបក្ខ៖

១- សុខ-ទុក្ខ

២- មានលាភ-ឥតលាភ

៣- មានយស-ឥតយស

៤- និន្ទា-សសើរ[៦]។

មនុស្សគ្រប់រូបត្រេកអរចង់បាន សុខ, ចង់មានលាភ, មានយស, និងចង់ឱ្យគេលើកសសើរខ្លួន មិនចង់បានទុក្ខ, មិន ចង់គ្មានលាភ, គ្មានយស, និងមិនចង់ឱ្យគេ និន្ទារិះគន់ខ្លួននោះទេ។ ប៉ុន្តែធម្មជាតិមិន បានបំពេញទៅតាមចិត្តមនុស្សចង់នោះទេ ពួកគេតែងតែខកបំណងនៅពេលលោកធម៌ទាំងនេះប្រែប្រួល។ លោកធម៌ប្រែថា ធម៌សម្រាប់មនុស្សលោកទូទៅ គ្រាន់តែកើតមានក្រាស់ស្ដើង ជាងគ្នាប៉ុណ្ណោះ។

## ៣- ប្រភព

ធម្មជាតិបានបង្កើតឱ្យមានវត្ថុច្រើនរាប់មិនអស់។ វត្ថុច្រើនរាប់មិនអស់នោះមានលក្ខណៈ **ខុសៗគ្នា**, ខ្វះខាត និង មិន គ្រប់គ្រាន់។ លក្ខណៈ **ខុសៗគ្នា, ខ្វះខាត** និង **មិនគ្រប់គ្រាន់** នេះតម្រូវឱ្យវត្ថុនានាទាំងនោះមានអត្ថិភាពដោយមិនឯករាជ្យ ពីវត្ថុដទៃៗទៀត។ ហេតុនេះពួកវាត្រូវតែពឹងអាស្រ័យគ្នាទៅវិញទៅមក ដោយជៀសពុំរួច ដើម្បីឱ្យមានអត្ថិភាពដោយពេញលេញ។ និយាយជារួម នៅក្នុងលោកនេះ គ្មានវត្ថុណាដែលមានអត្ថិភាពដោយឯករាជ្យពីវត្ថុដទៃនោះបានឡើយ។

**កង្វះខាតនៃអង្គវត្ថុ** នាំឱ្យកើតនូវ **ការពឹងអាស្រ័យគ្នា**។ **ការពឹងអាស្រ័យគ្នា** នាំឱ្យកើតនូវ **ការរត់រកគ្នា** ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមក។ ការរត់រកដើម្បីបំពេញឱ្យគ្នានេះគឺជា **ប្រភពនៃចលនា**។ ផ្ដើមចេញពី **កង្វះខាតនេះអង្គវត្ថុនានា** ត្រូវតស៊ូជាមួយគ្នារហូតដល់អស់អត្ថិភាព។ ការតស៊ូជាមួយគ្នា ដើម្បីបំពេញឱ្យ

---

[៥] -ដ-., ទំព័រ ១៣

[៦] ហុក សាវណ្ណ, "ការព្យាបាលរោគផ្លូវចិត្តតាមវិធីពុទ្ធសាសនា", វត្តខ្មែរកាណាដា, ទំព័រ ៨

គ្នានេះ ពេលខ្វះពួកវាអាចបំពេញឱ្យគ្នាបាន ពេល នោះ ***ការឯកភាពគ្នា*** ដែល ***អិមផេដូគ្លីហ្ស*** (Empédocle : ៤៨៣-៤២៣ មុនគ.ស.) ទស្សនវិទូក្រិកបូរាណហៅថា "***ការច្របល់ ឬស្នេហា***[7]" ក៏នឹងកើតឡើង ហើយប្រព្រឹត្ត ទៅដោយសុខសាន្តជាមួយគ្នា។ សុភាសិត ខ្មែរពោលថា"អ្នកមានរក្សាខ្សត់ ដូចសំពត់ ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅទូរសំប៉ាន។" ***ព្រះរាជសម្ភារ*** បានសរសេរថា "ខ្ញែងហើរដ្បិតខ្យល់ នាយថ្កើងដ្បិតពល រក្សាឱ្យសុខ ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុកដ្បិតភរិយាជា[8]" ***ការឯកភាព*** នៃអង្គវត្ថុប្រព្រឹត្តទៅជាមួយគ្នាដោយសុខដុម ដោយសារតែពួកវាមាន ***គុណភាព*** (qualities) និង ***សម្បត្តិ*** (pro-perties) ដូចគ្នា ឬប្រហាក់ប្រហែលគ្នា។ ប៉ុន្តែ ពេលខ្វះទៀត ពួកវាក៏មិនអាចបំពេញ ឱ្យគ្នាបាន ដោយសារតែពួកវាមាន ***គុណ ភាព*** (qualities) និង ***សម្បត្តិ*** (properties) មិនដូចគ្នា ឬខុសគ្នាទាំងស្រុងពេលនោះ ***វិសមភាព*** (unequal) រវាងគូរអន្តរកម្ម ក៏នឹងកើតឡើង។ ***វិសមភាព*** នាំឱ្យកើតនូវ ***ទំនាស់*** ដែល ***អិមផេដូគ្លីហ្ស*** ហៅថា "***ការបំបែក ឬកំហឹង***[9]" ក៏នឹងកើតឡើងដែរ គឺ នៅពេលនោះ ហើយដែល អង្គវត្ថុនីមួយៗ ត្រូវបំបែកចេញ ពីគ្នា និងក្លាយទៅជា ***គូទំនាស់*** ដែលយើងហៅថា ***គូរបដិបក្ខ***។ ***គូរបដិបក្ខ*** មានបែបដូចជា មនុស្សទល់នឹងមនុស្ស; មនុស្សប្រុសទល់នឹងមនុស្សប្រុស; មនុស្សប្រុសទល់នឹងមនុស្សស្រី; មនុស្សស្រី ទល់ នឹងមនុស្សស្រី ; មនុស្ស ទល់ នឹងរុក្ខជាតិ; រុក្ខជាតិទល់នឹងរុក្ខជាតិ; រុក្ខជាតិទល់នឹងសត្វ; សត្វទល់នឹងសត្វ... ល...។ អ្នកមានទល់នឹងអ្នកក្រ; អ្នកអយុត្តិ ធម៌ទល់នឹងអ្នកយុត្តិធម៌; អ្នកមនោនិយម ទល់នឹងអ្នក រូបធាតុនិយម...ល...។

គំនូសបំព្រួញអំពីអន្តរកម្មនៃអង្គវត្ថុ

- មនុស្ស ⇆ មនុស្ស
  ⇅ ⇅
- រុក្ខជាតិ ⇆ សត្វ ⇆ សត្វ
  ⇅
- រុក្ខជាតិ

កំណត់សម្គាល់

- ⇅ សញ្ញា ដែលអង្គវត្ថុនីមួយៗត្រូវពឹងអាស្រ័យ និងបំពេញឱ្យគ្នា។

ឧទាហរណ៍ គូស្រករប្ដីប្រពន្ធ បន្ទាប់ពីជួបគ្នា (ឯកភាព) ពួកគេក៏បែកគ្នា (ទំនាស់) រួចហើយក៏ជួបគ្នាវិញ (ឯកភាពថ្មីក្នុងដៃគូចាស់) បន្ទាប់មកក៏បែកគ្នាទៀត (ទំនាស់ថ្មីក្នុងដៃគូចាស់) មិនយូរប៉ុន្មានក៏បែកគ្នាទៀត (ទំនាស់ថ្មីក្នុងដៃគូចាស់) ទៅរកដៃគូថ្មីតែរៀងៗខ្លួន (ឯកភាពថ្មីក្នុងដៃគូថ្មី)។ នេះគឺជាទិដ្ឋភាពគំរូមូលដ្ឋានមួយដែលឆ្លុះ ឱ្យឃើញពីទិដ្ឋភាពនៃអង្គវត្ថុនានា នៅក្នុង ពិភពធម្មជាតិនេះ ដែលវត្ថុទាំងអស់

---

[៧] ឆយ យីហ៊ាង, ដ.ឯ.ម. ទំព័រ ៣០

[៨] លាង ហាប់អាន "ព្រះរាជាសម្ភារ", បោះពុម្ពលើក ទី៤, ភ្នំពេញ, ២០០៥,ទំព័រ ៣០

[៩] ឆយ យីហ៊ាង,ដ.ឯ.ម., ទំព័រ ៣០

សុទ្ធតែជួប-ព្រាត់-ជួប បែបនេះមិនចេះចប់។ គ្មានការជួបណាដែលមិនព្រាត់ ហើយក៏គ្មានការព្រាត់ណាដែលមិនជួប។ ការជួបជាបុព្វហេតុនៃការព្រាត់។ បើមិនចង់ព្រាត់ សូមកុំជួប។ ព្រះរាជសម្ភារ កវីរាជសតវត្សរ៍ ទី១៧ បានសរសេរពីក្រឹត្យក្រមប៉ះទង្គិចនៃអង្គវត្ថុ ដែលនាំទៅដល់ការព្រាត់ថា "ខ្មៅ វែងស្អប់ចេះ ខ្សត់ឥតចំណេះ ស្អប់អ្នកមាន ទ្រព្យ ស្រីស្រាប្រច័ណ្ឌ វែងស្អប់ខ្ញុំគាប់ ពាលពិតឥតច្បាប់ វែងស្អប់ប្រដៅ។ ចង់បុណ្យបានបាប ចចើងចង់លាភ វែងបាត់ធនទៅ មានះបាត់មិត្ត ឥតអ្នកជាផៅ ក្រេវក្រោធឃោរឃៅ រមែងបាត់អង្គ[10]។

**គំនូសបំប្រួញអំពីប្រព័ន្ធអេកូឡូស៊ី**

រុក្ខជាតិបង្កើតជាមូលដ្ឋានបណ្តាញអាហារ




គំនូសបំប្រួញអំពីប្រព័ន្ធពឹងអាស្រ័យនៃអង្គវត្ថុ



រូបថតស្រុកស្រែស្រុកកំណើត

[10] លាង ហាប់អាន ដ.ឯ.ម., ទំព័រ ៣៣

សរុបសេចក្តីមក ប្រភពនៃ **គំនិតបដិសំយោគ** ឬ **ទ្រឹស្តីបដិសំយោគ** ផ្តើមចេញពីអង្គវត្ថុធម្មជាតិមិនដូចគ្នា។

## ៤- ប្រភេទគូទំនាស់

គេអាចចោទសួរថា៖

- តើធម្មជាតិមានយុត្តិធម៌ដែរឬទេ?
- ហេតុអ្វីបានជាវត្ថុនានានៅក្នុងធម្មជាតិមិនដូចគ្នា?
- តើហេតុអ្វីបានវត្ថុនានាមានទំនាស់?

វត្ថុទាំងអស់នៅក្នុងធម្មជាតិសុទ្ធតែមិនដូចគ្នា។ គ្មានវត្ថុណាដែលដូចគ្នារហូតដល់ក្លាយទៅជាវត្ថុតែមួយ ហើយគ្មានទំនាស់គ្នានោះទេ[11]។ ពាក្យថា "ដូចគ្នា" មានន័យថា "ខុសគ្នា"។ ហេតុនេះ **ទំនាស់** កើតមកពី **ភាពមិនដូចគ្នានៃអង្គវត្ថុ**។ អង្គវត្ថុខុសគ្នាបណ្តាលមកពី **គុណភាព** និង **សម្បត្តិ** របស់ពួកវាខុសគ្នាតិច ឬទាំងស្រុង។ **គុណភាព** និង **សម្បត្តិ** ខិតមករក **ភាពដូចគ្នា** កាន់តែច្រើន **ទំហំទំនាស់** របស់ពួកវាក៏កាន់តែតិចទៅៗរហូតដល់ **ដូចគ្នា សុទ្ធសាធ** តែមិនមែនមានន័យថា **វត្ថុតែមួយ** នោះទេ។ នៅខណៈពេលដែល **គុណភាព** និង **សម្បត្តិ** ខិតមករក **ភាពដូចគ្នា** កាន់តែច្រើន **កម្លាំងនៃការឯកភាពគ្នា** ក៏កាន់តែស្អិតរមួត។ បើនិយាយពីគូស្រករ គឺស្រលាញ់គ្នារហូតដល់ "ខាំចេករបូតខាំពោតរបេះ"

[11] ឆយ យីហ៊ាង,ដ.ឯ.ម. ទំព័រ ៣៣

ដូចចាស់បុរាណលោកពោល។ ផ្ទុយទៅវិញ ប្រសិនបើ **គុណភាព** និង **សម្បត្តិ** របស់ពួកវា ខិតទៅរក **ភាពខុសគ្នា** កាន់តែច្រើន **ទំហំ ទំនាស់** របស់ពួកវាក៏កាន់តែខ្លាំងទៅៗ រហូត ដល់**បំបែកចេញ ពីគ្នា** អាចបែកនៅក្នុងកម្រិត បណ្ដោះអាសន្ន ឬបែកជារៀងរហូត។

គូទំនាស់របស់អង្គវត្ថុ អាចចែកជា ពីរ ក្រុមគឺ **គូទំនាស់រវាងអង្គវត្ថុនិងអង្គវត្ថុ** នៅក្នុង ធម្មជាតិ និង **គូទំនាស់រវាងគំនិត និងគំនិត** នៅ ក្នុងគំនិតរបស់មនុស្សម្នាក់ និងមនុស្សម្នាក់ ទៀត។ គូទំនាស់ទាំងពីរ នេះមានលក្ខណៈជា **នាម** (noun) ផង និង ជា**គុណនាម** (adjective) ផង។ ក្រុមទាំង ពីរនេះមានអន្តរកម្មជាមួយគ្នា ឱ្យផលជា **អវិជ្ជមាន** និង ជា **វិជ្ជមាន**។ **ផល អវិជ្ជមាន** សំដៅទៅលើផលដែលមានគុណភាព អសកម្ម, អន់ថយ, អន្តរាយ, វិនាស, ហិនហោច, ចង្រៃ, ក្ដៅក្រហាយ...ល។ និយាយ ជារួមគឺជា គុណភាពដែលនៅពេលវាប្រាស្រ័យទាក់ទង ជាមួយអ្វីមួយ ឬអ្វីមួយមកប្រាស្រ័យទាក់ទង ជាមួយវា អ្វីមួយនោះ នឹងត្រូវចុះ អន់ថយ ទាប គ្មានតម្លៃ។ នៅ ក្នុងជីវិតរស់នៅមនុស្សជាច្រើន មិនចង់បានផលនេះទេ។ ចំណែកឯ **ផលវិជ្ជមាន** សំដៅទៅលើផលដែលមានគុណភាពសកម្ម, ចម្រើន, រុងរឿង, ល្អតលាស់, ដុះដាល, សិរី សួស្ដី, ល្អ, ត្រជាក់ត្រជុំ...ល ...។ នៅពេលដែល វាប្រាស្រ័យទាក់ទង ឬ អ្វីមួយមកប្រាស្រ័យ ទាក់ទងជាមួយវា អ្វីមួយនោះនឹងត្រូវរីក លូតលាស, ដុះដាល, សុខដុម។ នៅក្នុងជីវិត រស់នៅ មនុស្សជា ច្រើនចង់បានផលបែបនេះ។

ទាក់ទងទៅនឹង **ផលអវិជ្ជមាន** និង **ផល វិជ្ជមាន** នេះ ផ្លេតូ (Plato) បានលើក ឧទាហរណ៍ ថា នៅលើ **ឋានសួគ៌** មានព្រះរាជរថមួយរបស់ ទេវតា។ ព្រះរាជរថនោះ ត្រូវដឹកដោយ **សេះពីរ ក្បាល**។ **ព្រលឹង អមតៈ** ឋិតនៅលើព្រះរាជរថ នោះ។ **សេះ ទីមួយ** មាន **សេចក្ដីក្លាហាន** និង មាន **សុធម្មៈ**។ **សេះទី២** ពោពេញទៅដោយ **តណ្ហាអកុសល**។ នៅពេលដែល **សេះទី២** មាន កម្លាំងជាង **សេះទី១** **ព្រះរាជរថ** ត្រូវធ្លាក់ចុះមក នៅ **ស្ថានកណ្ដាល** ដោយធ្វើឱ្យ ភ្លេចអស់នូវ អ្វីៗដែលធ្លាប់មាននៅក្នុង **ពិភពគំនិត** ដ៏ សក្ដិសិទ្ធិ។ ហេតុនេះ **ព្រលឹង អមតៈ** មិនអាច យល់ពី **គំនិត** បានឡើយ។ ផ្ទុយទៅវិញ នៅ ពេលដែល **សេះទី១** មាន កម្លាំងជាង **សេះទី២** **ព្រះរាជរថ** ត្រូវឡើង ទៅ **ឋានសួគ៌** វិញ រហូត ទៅដល់ **ពិភពគំនិត**។ នៅពេលនេះ **ព្រលឹង** សង្កេតឃើញ **គំនិត** យល់ច្បាស់ ស្មារតីយល់ ច្បាស់ **វិចារណញ្ញាណ** ដែលគ្មានរូបរាង គ្មាន ពណ៌សម្បុរ និងគ្មានឥន្ទ្រិយារម្មណ៍។ នោះគឺ ជា **ព្រលឹងឧត្ដុងឧត្ដម**[12]។

នៅក្នុងព្រះពុទ្ធសាសនាក៏មានការបក ស្រាយស្រដៀងនឹងផ្លេតូនេះដែរ ទាក់ទងទៅ នឹង **កុសលកម្ម** (good Kamma ) និង **អកុសលកម្ម** ឬ **បាបកម្ម** (evil Kamma)។ មនុស្សម្នាក់បើមាន គំនិតបាប ឬ អាក្រក់ច្រើន គំនិតបាប ឬអាក្រក់

[12] ឆយ យីហ៊ាង,ដ.ឯ.ម., ទំព័រ ៦១

នេះនឹងជម្រុញខ្លួនគេ ដែលផ្ទុយពីថា រាជវថ ឱ្យប្រព្រឹត្តអំពើបាបឬអាក្រក់ច្រើន ដែរ ពោលគឺ **ចុះនរក** ក្នុងន័យថា ជីវិតក្រលំបាក វេទនា ឬក៏ត្រូវគេវាយធ្វើបាបអាចនឹងដល់ស្លាប់ក៏ថាបាន។ ផ្ទុយទៅវិញ បើមនុស្សម្នាក់នោះមានគំនិតល្អ ប្រកបដោយកុសលធម៌, សុចន្ទៈ, និង គុណធម៌ច្រើន គំនិតល្អប្រកបដោយកុសលធម៌, សុចន្ទៈ, និងគុណធម៌នេះនឹងជម្រុញខ្លួន គេឱ្យប្រព្រឹត្តអំពើល្អ ប្រកបដោយកុសល ធម៌, សុចន្ទៈ, និងគុណធម៌ច្រើនដែរ គឺនៅ ពេលនោះហើយដែលជីវិតរបស់គេឡើងឋានសួគ៌ ពោលគឺ ជីវិតសុខសាន្ត មិនសូវជាមានការរំខានពីភាពក្រក្រី ឬបាបមនុស្ស មានសិរីសួស្តី មានមនុស្សរាប់អានច្រើន មានអ្នកជួយយករក្សា រកស៊ីមានបានមានបុណ្យស័ក្តិឋានៈខ្ពង់ខ្ពស់ រស់នៅថ្ងៃថ្នូរដូចទេវតា។

ខាងក្រោមនេះគឺជាគូទំនាស់ជានាម និងជាគុណនាមៈ

គូទំនាស់ជានាម

- មនុស្សនិយម-ទេវនិយម
- កុម្មុយនិស្តនិយម-សេរីនិយម
- មនោនិយម-រូបជាតុនិយម
- លទ្ធិពុទ្ធរាជ-លទ្ធិទេវរាជ
- អ្នកក្រ-អ្នកមាន
- ប្រពន្ធ-ប្តី
- មិត្ត-សត្រូវ
- អវិជ្ជា-វិជ្ជា
- កម្មករ-មូលធនិក
- ប្រជាជន-អ្នកដឹកនាំ
- សង្គ្រាម-សន្តិភាព
- អពមង្គល-សុភមង្គល
- អកុសល-កុសល
- យប់-ថ្ងៃ
- ស្រី-ប្រុស

គូទំនាស់ជាគុណនាម

- ស្រាល-ធ្ងន់
- មូល-សំប៉ែត
- លំបាក-ស្រួល
- អាក្រក់-ល្អ
- ខ្មៅ-ស
- តូច-ធំ
- ទាប-ខ្ពស់
- ក្រ-មាន
- ស្អុយ-ក្រអូប
- ងងឹត-ភ្លឺ
- ខុស-ត្រូវ
- ឆ្ងាយ-ជិត
- ល្ងង់-ឆ្លាត
- ក្បត់-ស្មោះត្រង់
- កាច-ស្លូត
- ខ្លី-វែង
- សើម-ស្ងួត
- ស្អុយ-ក្រអូប
- ថោក-ថ្លៃ
- កំសាក-ក្លាហាន

*ខ្ជិល-ឧស្សាហ៍*

*កេង-សប្បុរស*

*វៀច/កោង-ត្រង់*

*ស្ដឹក-រួស*

*ញី-ឈ្មោល*

*គូទំនាស់ជានាម ជាគូទំនាស់ដែល មាន លក្ខណៈជានាមពីពីធម្មជាតិ ឬពី កំណើត ដោយខ្លួនវា។ ឯគូទំនាស់ជាគុណនាមជាគូ ទំនាស់ដែលគ្រាន់តែជាការបន្ថែម ឬបំពេញ ន័យ ឬគុណភាពឱ្យនាមតែប៉ុណ្ណោះ។ វាមាន លក្ខណៈមិនឯកពជ្យទេ។*

*គូទំនាស់រវាងអង្គវត្ថុ ដូចជា មនុស្ស និង មនុស្ស, មនុស្សនិងវត្ថុ...ល...។ មាន ពន្យល់រួច នៅចំណុចទី៣។ ចំណែកឯគូ ទំនាស់រវាង គំនិតមានពន្យល់នៅទីនេះ។*

*តើទំនាស់ ឬជម្លោះរវាងបុគ្គលនិង បុគ្គល, រវាងគ្រួសារនិងគ្រួសារ, រវាង ប្រទេស និងប្រទេស ឬចោទសួរជារួមថា តើសង្គ្រាម នៅក្នុងពិភពលោក តាំងពីអតីតកាល ដូចជា សង្គ្រាមលោកលើកទី១ ទី២ និងសង្គ្រាមនៅ ក្នុងពិភពលោកសព្វថ្ងៃរវាងរុស្ស៊ីនិងអ៊ុយក្រែន, ហាម៉ាសនិង អ៊ីស្រាអែល, ជម្លោះនៅសហភាព មីយ៉ាន់ម៉ា បណ្ដាលមកពីអ្វី?*

*ចរន្ត "គំនិត" ត្រូវបានចែកទៅជា ចរន្ត គំនិតខុស និងចរន្តគំនិតត្រូវ, ចរន្ត គំនិតល្អ និង ចរន្តគំនិតអាក្រក់, ចរន្តគំនិត វិជ្ជមាន និង ចរន្តគំនិតអវិជ្ជមាន។ ចរន្តទាំង ពីរបែបនេះ មានធម្មជាតិមិនដូចគ្នាទេ។ វា តែងតែប៉ះទង្គិច គ្នាហើយបង្កទៅជាទំនាស់, ជម្លោះ, ឬសង្គ្រាម រវាងគ្នា ពោលគឺ រវាង បុគ្គលនិងបុគ្គល, គ្រួសារ និងគ្រួសារ, ប្រទេសនិងប្រទេស។ អ្នកចូលចិត្ត ស្រា យល់ថា ស្រាល្អ ឯអ្នកស្អប់ស្រាវិញយល់ ថាស្រាធ្វើឱ្យខូចសុខភាព។ អ្នកស្អប់គំនូរអាក្រាត កាយយល់ថា គំនូរអាក្រាតកាយ មានលក្ខណៈ អាសអាភាស តែសម្រាប់វិចិត្រករដែលស្រលាញ់ គំនូរយល់ថាគំនូរបែបនេះល្អ។ ហេតុនេះគំនូរ អាក្រាតកាយ ក៏មានអត្ថិភាព។ ពួកកុម្មុយនិស្ត យល់ថា ស៊ូសម្លាប់ខុសប្រសើរជាជាងឱ្យឧក្រិដ្ឋ ជនរួចខ្លួន ដែលផ្ទុយទៅនឹងគំនិតរបស់ពួក លោកសេរីដែលយល់ថា ស៊ូឱ្យឧក្រិដ្ឋជនរួចខ្លួន ប្រសើរជាជាងសម្លាប់ខុស។ នៅក្នុងរឿងសាមកុក ឆាវៗ យល់ថា សុខចិត្តឱ្យ ខ្លួនគាត់ក្បត់ពិភព លោក តែមិនឱ្យពិភពលោកក្បត់គាត់នោះ ឡើយ។ អ្នកសម្ភារៈនិយមយល់ថា ការតុបតែង លំអរូបរាង កាយល្អប្រសើរជាងការតុបតែង លំអ ព្រលឹង (ចិត្តគំនិត) តែរឿងនេះផ្ទុយទៅ នឹងគំនិតខ្មែរបុរាណដែលលើកឡើងថា "រូប សដូចចានមាយាទមិនបានដូចឆ្កែ ក្រោមផ្ទះ" ដែលស្របជាមួយនឹងគំនិត ហ្សីណូ ហ្វ៊ែន (Xenophanes: ៥៧០-៤៧៨ មុនគ.ស) ទស្សន វិទូក្រិកដែលយល់ថា "**បញ្ញា** ភ្លឺថ្លាប្រសើរជាង **កម្លាំងមនុស្ស** និង **កម្លាំងសេះ**។[13]" ផ្ទេចូយល់ ថា "**លំអពិត** ជាលំអរបស់គំនិត ដែលខុសពី*

*១៣ ឆយ យីហ៊ាង,ជ.ឯ.ម. ទំព័រ ១៧*

លំអរបស់ **វត្ថុវេទយិត**។ លំអនៃគំនិតល្អថ្លៃថ្លា មាន **អត្ថិភាពអមតៈ** នៅក្រៅ **លំហ** ក្រៅ **កាល** និង **ឥតប្រែប្រួល**។ លំអនៃ **វត្ថុវេទយិត** ជាលំអធៀប និងប្រែប្រួលជារឿយៗ"[14]

នៅក្នុងទស្សនវិជ្ជា មាននិកាយពី ដែលតែងតែមានចរន្តគំនិតផ្ទុយគ្នា។ ចរន្តទី១ គឺ "លទ្ធិមនោនិយម (idealism)។ ចរន្តទី២ គឺលទ្ធិរូបជាតុនិយម (materialism)"។ នៅក្នុងដំណើរកកើតនិងការរីកចម្រើននៃទស្សនវិជ្ជាក្រិកបូរាណសម័យ លទ្ធិទាំង ពីរនេះបានផ្សាភ្ជាប់នឹងការតស៊ូជាមួយគ្នា យ៉ាងស្មុគស្មាញបំផុត។ ការតស៊ូទស្សនវិជ្ជានេះឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវការ តស៊ូរវាងស្រទាប់ពីរនៅក្នុងវណ្ណៈម្ចាស់ទាសករ ពោលគឺស្រទាប់ **ម្ចាស់ទាសករប្រជាធិបតេយ្យហើយនិងម្ចាស់ទាសករអភិជន**[15]។

**លទ្ធិមនោនិយម** បើតាមផ្លេថូយល់ ថា **គំនិត** (idea) **កើតមុនអត្ថិភាព**។ **អត្ថិភាព** (existence) កើតក្រោយ **គំនិត**។ មនុស្ស, សត្វ, រុក្ខជាតិ, សុទ្ធសឹងជា **អត្ថិ- ភាព** ឬជា **ធម្មជាតិ** ឬ **ជាវត្ថុវេទយិត**។ អ្វីៗ ទាំងអស់នោះគឺសុទ្ធតែកើតចេញពី **គំនិត**។ ចាស់បូរាណខ្មែរពោលថា មានគំនិតទើបមានកំណើត ឬក៏ថា អត់កំណើតមកពីអត់គំនិត។ **គំនិត** ឥតប្រែប្រួលទេ។ **វត្ថុវេទយិត** តែងកើតប្រែប្រួលនិងស្លាប់ទៅវិញ។ ហេតុនេះ **វត្ថុវេទយិត** គឺជាកម្មវត្ថុពុទ្ធិ **ស្រមើស្រមៃ** ជា **ស្រមោលនៃគំនិត** គឺពុំមែនជាកម្មវត្ថុនៃចំណេះពិតឡើយ។ ហេតុ នេះមានតែ **គំនិត** ទេដែលមាន **អត្ថិភាព អមតៈ**។ វាមានអត្ថិភាពនៅក្រៅ **លំហ** និង **កាល**។ លោកយល់ថា **គំនិត** ជា **ភាវៈរូបធាតុ** ជា **អភាវៈ**។ **វត្ថុវេទយិត** ស្ថិតនៅចន្លោះ **ភាវៈ** និង **អភាវៈ**។ **វត្ថុវេទយិត** ជា **ស្នាមគំនូសនៃ គំនិត**[16]។

ចំពោះចរន្តគំនិតនៃ **លទ្ធិរូបជាតុនិយម អ៊ែរីស្តូតឹល** (Aristotle) យល់ខុស ស្រឡះពីទ្រឹស្តីគំនិតរបស់ ផ្លេថូ។ នៅក្នុងដំណោះស្រាយរវាង **អត្ថិភាព** និង **គំនិត** **អ៊ែរីស្តូតឹល** យល់ថា **អត្ថិភាពកើតមុន គំនិត**។ រីឯផ្លេថូយល់ថា **អត្ថិភាព** ជាស្រមោលនៃគំនិត ឬ **គំនិតកើតមុនអត្ថិ-ភាព**។ ហេតុនេះ **អ៊ែរីស្តូតឹល**យល់ថា ពិភពលោកមាន **អត្ថិភាពបរានុម័ត**[17]។

## សេចក្តីសន្និដ្ឋាន

វត្ថុទាំងអស់នៅលើផែនដីនេះសុទ្ធតែមានអន្តរទំនាក់ទំនងជាមួយគ្នាជាចាំបាច់។ ការមានអន្តរទំនាក់ទំនងជាមួយគ្នា ជាចាំបាច់នេះ ដោយសារតែពួកវាមាន លក្ខណៈមិនគ្រប់គ្រាន់ ហើយពួកវាត្រូវការគ្នាដើម្បីបំពេញឱ្យគ្នាដើម្បីបន្តមាន អត្ថិភាពដោយពេញលេញ។ ពេលខ្លះពួក វាអាចបំពេញឱ្យគ្នាបាន ក៏មានការឯកភាពគ្នា ហើយបន្តមានសហត្ថិភាព

---

[១៤] -ដ-. ទំព័រ ៦៣

[១៥] -ដ-. ទំព័រ ៥

[១៦] ឆយ យីហ៊ាង,ទំព័រ., ៥៨-៥៩

[១៧] - ដ- ៦៩-៧០

ជាមួយគ្នា។ ប៉ុន្តែ នៅពេលខ្លះពួកវាមិនអាចបំពេញឱ្យគ្នាបាន ពេលនោះទំនាស់ក៏កើតឡើង។ វត្ថុ ត្រូវបំបែកចេញពីគ្នា។ វត្ថុថ្មីក៏ចាប់មាន អត្ថិភាពឡើង។

ហេតុនេះ ការសិក្សាពីអង្គវត្ថុនីមួយ គឺជាការរកឃើញពីតម្រូវការចាំបាច់, ពី **ការឯកភាព, ទំនាស់, ការបំបែក**, និងពី **ការសំយោគ** ឬ **ការកើតថ្មី** របស់ពួកវា។ ការយល់ដឹងពីចំណុចទាំងនេះ ជួយឱ្យយើង យល់បានពីគ្រឹត្យក្រមទំនាក់ទំនង, ការ ថែរទាំ, បុព្វហេតុនៃការចម្រើន, និងការចុះអន់ថយនៃអង្គវត្ថុ ដើម្បីឈានទៅរកការគ្រប់គ្រង ក៏ដូចជាការប្រាស្រ័យទាក់ទង ដោយសុខដុមជាមួយគ្នាដែរ។

សព្វថ្ងៃនេះ ដំណើរអន្តរកម្មរវាង **មនុស្សនិងមនុស្ស**; រវាង **មនុស្សនិងធម្មជាតិ**; និងរវាង **ធម្មជាតិនិងមនុស្ស**។ មនុស្សរស់បានដោយពឹងលើធម្មជាតិ។ ឯ ធម្មជាតិក៏ត្រូវពឹងលើមនុស្សដើម្បីជួយ ថែរក្សាវាវិញដែរ។ ប៉ុន្តែបើមនុស្សមិន ត្រឹមតែដើម្បីរស់ ពួកគេមានមហិច្ឆតា លោភ ពួកគេនឹងត្រូវធ្វើសង្គ្រាមដើម្បីបំផ្លាញគ្នា, ដើម្បីដណ្តើមផលប្រយោជន៍, ដើម្បីដណ្តើមការគ្រប់លើគ្នា, និងដើម្បីដណ្តើមប្រមូលយកធនធានធម្មជាតិតែម្នាក់ឯង។ ដើម្បីឈ្នះចាញ់គ្នាក្នុងរឿងនេះ មនុស្សត្រូវយកធនធានធម្មជាតិធ្វើជាដើមទុន (បំផ្លាញធម្មជាតិ) ដើម្បីធ្វើសព្វាវុធប្រយុទ្ធគ្នា។ នៅពេលមនុស្សប្រើប្រាស់ធនធានធម្មជាតិដោយខ្ជីខ្ជាច្រើនហួសប្រមាណនិងដោយខ្វះមនសិការ ធនធានធម្មជាតិនឹងត្រូវវិនាសហិនហោច ហើយជាផលសងត្រឡប់មកវិញរបស់ធម្មជាតិ គឺ ការរញ្ជួយដី, ទឹកជំនន់, កំណើនកំដៅផែនដី, ខ្យល់ព្យុះ, គ្រោះរាំងស្ងួត។ ទីបំផុត មនុស្សបំផ្លាញធម្មជាតិ ៗក៏នឹងបំផ្លាញមនុស្សវិញដែរ។ ហេតុនេះ ការយល់ដឹងពីគូបដិបក្ខនៃអង្គវត្ថុមានសារប្រយោជន៍សម្រាប់ការរស់នៅដោយសុខសាន្តជាមួយធម្មជាតិ។

## គន្ថនិទ្ទេស


I- *ស្នាដៃនិពន្ធជាភាសាខ្មែរ*

*១- ឆយ យីហ៊ាង,"ប្រវត្តិទស្សនវិជ្ជា បស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជា បូរាណសម័យក្រិក",*
*សាកលវិទ្យា- ល័យភូមិន្ទភ្នំពេញ, ១៩៩៤*

២- លាង ហាប់អាន *"ព្រះរាជាសម្ភារ(កវីរាជស.វ. ទី១៧)"*, បោះពុម្ពលើកទី ៤, ភ្នំពេញ, ២០០៥

៣- ហុក សាវណ្ណ, *"ការព្យាបាលរោគផ្លូវចិត្តតាមវិធីពុទ្ធសាសនា"*, វត្តខ្មែរ កាណាដា

II- *ស្នាដៃនិពន្ធជាភាសាអង់គ្លេស*

1- Venancio B. Ardales, *Introductory Text to Philosophy*, 2nd Ed., New York, 1987